**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

LAND

JS LAND PLC

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**

លេខ ២៨១៣/០២៣/ជអក ជ.អ.ល.

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២៣

# លិខិតជូនដំណឹង

## ស្តីពី

## ការកែតម្រូវរបៀបវារៈ នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ ដែលបានផ្សព្វផ្សាយនៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី (ជ.អ.ល.)** មានកិត្តិយសសូមជម្រាបជូនភាគហ៊ុនិកទាំងអស់របស់ ជ.អ.ល. មេត្តាជ្រាបថា ក្រុមហ៊ុនសូមធ្វើការកែតម្រូវរបៀបវារៈនៅក្នុងសេចក្តីជូនដំណឹង លេខ២០២៣/០០៩/ផមក ជ.អ.ល របស់ក្រុមហ៊ុន ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ដែលមានព័ត៌មានលម្អិតក្នុងការកែតម្រូវរបៀបវារៈដូចខាងក្រោម៖

### ការកែតម្រូវរបៀបវារៈមុន

| មុនការកែតម្រូវ | ក្រោយការកែតម្រូវ |
|---|---|
| **លេខ ២ – ការបើកកិច្ចប្រជុំ**<br><br>២.១ – ការណែនាំសមាសភាពអ្នកចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ<br><br>២.២ – គោរពភ្លេងជាតិកម្ពុជា<br><br>២.៣ – មតិស្វាគមន៍របស់ **លោកឧកញ៉ា ភួយ ឡេសាន** ប្រធានក្រុមប្រឹក្សាភិបាលរបស់ ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី | **លេខ ២ – ការបើកកិច្ចប្រជុំ**<br><br>២.១ – ការណែនាំសមាសភាពអ្នកចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ<br><br>២.២ – គោរពភ្លេងជាតិកម្ពុជា<br><br>២.៣ – មតិស្វាគមន៍របស់ **លោកឧកញ៉ា ភួយ ឡេសាន** ប្រធានក្រុមប្រឹក្សាភិបាលរបស់ ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី<br><br>២.៤ – ការណែនាំអំពីកិច្ចការ សម្រាប់ការបោះឆ្នោតសម្រេច |

ចុះបញ្ជីក្រោមលេខ
Registration No. 00010332

លេខ B២-១០៧ អគារ The Elysee កោះពេជ្រ វិថីកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#B2-107, The Elysee Diamond Island, Koh Pich Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 010 88 66 99
E-mail: info@jslandplc.com, Website: www.jslandplc.com

| **លេខ ៣ – សេចក្តីសម្រេចការបោះឆ្នោត** | **លេខ ៣ – សេចក្តីសម្រេចការបោះឆ្នោត** |
|---|---|
| ក. ការអនុម័តលើការតែងតាំងប្រគល់សិទ្ធិជូន លោក Yap Maow Jun អភិបាលមិនប្រតិបត្តិ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីក្នុងនាមជាតំណាងភាគហ៊ុនិកសាធារណៈ។ | ក. ការបោះឆ្នោតអនុម័ត និងយល់ព្រម ប្រគល់សិទ្ធិអំណាចពេញលេញជូន ក្រុមប្រឹក្សាភិបាល ដើម្បី (i) ចុះកិច្ចសន្យា អនុវត្ត និងចុះហត្ថលេខា លើរាល់កិច្ចសន្យា និង/ឬ កិច្ចព្រមព្រៀងគ្រប់ប្រភេទ (ដែលរួមមានជាអាទិ៍ កិច្ចព្រមព្រៀងកម្ចី កិច្ចសន្យាទិញ និង/ឬលក់ដី ។ល។) (“**កិច្ចព្រមព្រៀង**”) ដែលកិច្ចព្រមព្រៀងនីមួយៗមានតម្លៃរហូតដល់ត្រឹមចំនួន **៥.០០០.០០០ ដុល្លារអាមេរិក** ក្នុងនាម និងជាតំណាងឲ្យក្រុមហ៊ុន ជ.អ.ល (ii) ធ្វើនូវរាល់កិច្ចការ និង/ឬសកម្មភាពនានា ដើម្បីផ្តល់អានុភាព ដល់ការចុះកិច្ចសន្យា ការអនុវត្ត និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងខាងលើនេះ និង (iii) ចាត់រាល់វិធានការ និង/ឬធ្វើនូវរាល់សកម្មភាពនានា ដែលក្រុមប្រឹក្សាភិបាលយល់ថាចាំបាច់ ឬសមស្រប សម្រាប់គោលបំណងខាងលើ។ |
| ខ. ការអនុម័តលើការតែងតាំងប្រគល់សិទ្ធិជូន (i) លោកឧកញ៉ា គួយ ឡេសាន ប្រធានក្រុមប្រឹក្សាភិបាល និង (ii) លោក Dato’ Yap Ting Chiat អគ្គនាយកប្រតិបត្តិ/អភិបាលប្រតិបត្តិរបស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីក្រោមចំនួន ២.០០០.០០០ ដុល្លារអាមេរិក ក្នុងនាមជាតំណាងក្រុមហ៊ុននិងតំណាងភាគហ៊ុនិកសាធារណៈ។ | ខ. ការបោះឆ្នោតអនុម័ត និងយល់ព្រមឱ្យក្រុមប្រឹក្សាភិបាលប្រគល់សិទ្ធិអំណាចបន្ត ដល់ (i) លោកឧកញ៉ា គួយ ឡេសាន ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ និង (ii) លោក Dato Yap Ting Chiat នាយកប្រតិបត្តិ/អភិបាលប្រតិបត្តិរបស់ក្រុមហ៊ុន ជ.អ.ល (“**អ្នកតំណាង**”) ក្នុងការ (ក) ចុះកិច្ចសន្យា អនុវត្ត និងចុះហត្ថលេខា លើរាល់កិច្ចសន្យា និង/ឬ កិច្ចព្រមព្រៀងគ្រប់ប្រភេទ (ដែលរួមមានជាអាទិ៍ កិច្ចព្រមព្រៀងកម្ចី កិច្ចសន្យាទិញ និង/ឬលក់ដី ។ល។) (“**កិច្ចព្រមព្រៀង**”) ដែលកិច្ចព្រមព្រៀងនីមួយៗមានតម្លៃរហូតដល់ត្រឹមចំនួន **២.០០០.០០០ ដុល្លារអាមេរិក** ក្នុងនាម និងជាតំណាងឲ្យក្រុមហ៊ុន ជ.អ.ល (ខ) ធ្វើនូវរាល់កិច្ចការ និង/ឬសកម្មភាពនានា ដើម្បីផ្តល់អានុភាព ដល់ការចុះកិច្ចសន្យា ការអនុវត្ត និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងខាងលើនេះ និង (គ) ចាត់រាល់វិធានការ និង/ឬធ្វើនូវរាល់សកម្មភាពនានា ដែលអ្នកតំណាងយល់ថាចាំបាច់ ឬសមស្រប សម្រាប់គោលបំណងខាងលើ។ |
| គ. ការអនុម័តលើការតែងតាំងប្រគល់សិទ្ធិជូនក្រុមប្រឹក្សាភិបាលទាំងអស់របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាក់កម្ចីច្រើនជាងចំនួន ២.០០០.០០០ ដុល្លារអាមេរិក ទៅដល់ ៥.០០០.០០០ ដុល្លារអាមេរិក ក្នុងនាមជាតំណាងក្រុមហ៊ុន និងតំណាងភាគហ៊ុនិកសាធារណៈ។ | |

សេចក្តីដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិក របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ទាំងអស់មេត្តា ជ្រាបជាព័ត៌មាន ដោយក្តីអនុគ្រោះបំផុត។

**ជ.គណៈកម្មាធិការរៀបចំកិច្ចប្រជុំមហា**

**សន្និបាតភាគហ៊ុនិកវិសាមញ្ញ**

**ប្រធាន**

ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី JS LAND PLC KINGDOM OF CAMBODIA

**កួយ ឡេសាន**